ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា
គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ
ប្រឆាំងការសម្អាតប្រាក់ និង
ហិរញ្ញប្បទានភេរវកម្ម (គ.ស.ហ)

លេខ ១២ ០១៧ ៧២៤ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញព្រះរាជក្រមលេខ នរ/រកម/០៦១៣/០០៦ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៩ និងមាត្រា៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា១ នៃអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញសេចក្តីសម្រេចលេខ ៨៧.សសរ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- យោងសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាល លេខ៨៧៥ សជណ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៦២៦ ១១៧

- យោងស្មារតីអង្គប្រជុំគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ហៅកាត់ថា "**ក.ប.ស.ហ**" ក្នុងគោលបំណងឆ្លើយតបអនុសាសន៍របស់ក្រុមការងារហិរញ្ញវត្ថុ និងជាយន្តការប្រតិបត្តិការអចិន្ត្រៃយ៍សម្រាប់ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម របស់គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (គ.ស.ហ)។

**ប្រការ ២.-**

**ក.ប.ស.ហ** មានសមាសភាពមកពីក្រសួង-ស្ថាប័ន ដូចខាងក្រោម៖

- តំណាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ចំនួន ១រូប — ប្រធាន
- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំនួន ១រូប — អនុប្រធាន
- តំណាងអង្គភាពប្រឆាំងអំពើពុករលួយ ចំនួន ១រូប — អនុប្រធាន
- តំណាងក្រសួងយុត្តិធម៌ ចំនួន ១រូប — អនុប្រធាន
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន ១រូប — សមាជិក
- តំណាងធនាគារជាតិនៃកម្ពុជា ចំនួន ១រូប — សមាជិក
- តំណាងក្រសួងមហាផ្ទៃ ចំនួន ៤រូប រួមមាន តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នាយកដ្ឋានកិច្ចការសមាគមនិងគណបក្សនយោបាយ — សមាជិក
- តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ចំនួន ១រូប — សមាជិក
- តំណាងក្រសួងពាណិជ្ជកម្ម ចំនួន ១រូប — សមាជិក
- តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចំនួន ១រូប — សមាជិក
- តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំនួន ១រូប — សមាជិក
- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន ចំនួន ១រូប — សមាជិក
- តំណាងលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម ចំនួន ១រូប — សមាជិក
- តំណាងលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ចំនួន ១រូប — សមាជិក
- តំណាងអគ្គនាយកដ្ឋានពន្ធដារ ចំនួន ១រូប — សមាជិក
- តំណាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ចំនួន ១រូប — សមាជិក

- តំណាងគណៈកម្មការមូលបត្រកម្ពុជា ចំនួន ១រូប សមាជិក
- តំណាងក្រុមប្រឹក្សាជាតិគណនេយ្យ ចំនួន ១រូប សមាជិក
- តំណាងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចំនួន ១រូប សមាជិក

**ប្រការ ៣.**~

ក.ប.ស.ហ មានមុខងារ និងភារកិច្ច ដូចខាងក្រោមៈ

ក. រៀបចំផែនការសកម្មភាព និងឆ្លើយតបលទ្ធផលរបាយការណ៍វាយតម្លៃអញ្ញមញ្ញស្តីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម តាមតួនាទី និងការទទួលខុសត្រូវរៀងៗខ្លួន

ខ. អនុវត្តក្របខ័ណ្ឌប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

គ. រាយការណ៍ពីលទ្ធផលនៃការអនុវត្តការងារជូន គ.ស.ហ ជាប្រចាំគ្រា

ឃ. រៀបចំឯកសារទាំងអស់ជាខេមរៈភាសា និងភាសាអង់គ្លេស តាមតួនាទីនិងការទទួលខុសត្រូវរបស់សមាជិកនីមួយៗ

ង. បំពេញការងារផ្សេងៗជាមួយក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់

ច. អនុវត្តសេចក្តីសម្រេច និងការងារផ្សេងៗទៀតដែល គ.ស.ហ ប្រគល់ជូន។

**ប្រការ ៤.**~

អនុប្រធាន និងសមាជិក **ក.ប.ស.ហ** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ឬមានភារកិច្ចផ្សេង អនុប្រធានត្រូវដឹកនាំប្រជុំជំនួសតាមការប្រគល់ភារកិច្ចពីប្រធាន។ ប្រធាន **ក.ប.ស.ហ** អាចអញ្ជើញមន្ត្រីតំណាងក្រសួង-ស្ថាប័នផ្សេងទៀតឲ្យចូលរួមប្រជុំតាមការចាំបាច់។

**ប្រការ ៥.**~

សមាជិកនីមួយៗនៃ **ក.ប.ស.ហ** ជាមន្ត្រីបង្គោលរបស់សាមីក្រសួង-ស្ថាប័ន និងមានសិទ្ធិបង្កើតក្រុមការងាររងតាមក្រសួង-ស្ថាប័នរៀងៗខ្លួន។

**ប្រការ ៦.**~

ប្រធាន គ.ស.ហ អាចបង្កើតក្រុមការងាររងរបស់ **ក.ប.ស.ហ** មានជាអាទិ៍ ក្រុមការងាររងផ្នែកត្រួតពិនិត្យ និងក្រុមការងាររងផ្នែកអនុវត្តច្បាប់ តាមសំណើរបស់ប្រធាន **ក.ប.ស.ហ**។

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨.-**

សមាជិក ក.ប.ស.ហ ដែលមានចែងក្នុងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចនិងការទទួលខុសត្រូវរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៧

**ប្រធាន ក.ស.ហ**

**ជា.ចាន់តូ**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២ ដើម្បីអនុវត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ